# គណបក្ស សម រង្ស៊ី-សហរដ្ឋអាមេរិក

## SAM RAINSY PARTY - UNITED STATES OF AMERICA

**សីលធម៌ សច្ចធម៌ យុត្តិធម៌**

គណបក្ស សម រង្ស៊ី
សាខាប្រចាំសហរដ្ឋអាមេរិក


Honorary President
*Mr. Dikhayuko Sen*

President
*Mr. Kim Ly Chea*

Vice President
*Mrs. Sophanny Bay*

Secretary General
*Mr. Tha Oum*
Deputy SG
*Mr. Tithia Sum*

Treasurer
*Mr. Mardi Seng*
Deputy Treasurer
*Mr. Synoun Kham*

Public Relations
*Mr. Marin Meas*

Membership
*Mr. Sakal Kim*

ID-Card Dept.
*Mr. Eng S. Neang*

Fundraising
*Mr. Tithia Sum, Chair*
*Mr. Cata Chiv*

Policy & Procedures
*Mr. Kovid Ho*

Litigation Council
*Mr. Vandy Sem, Chair*
*Dr. Yorn Meas,*
*Att. Sovantara Neang*
*Mr. Sreng Van*

Advisors
*Mr. Pheach Srey*
*Mr. Sovann Ou*
*Mr. Kunno Prak*
*Mrs. Raci Say*


# សេចក្ដីថ្លែងអំណរគុណ

យុទ្ធនាការឃោសនាសំរាប់ការបោះឆ្នោតសាកលជាប្រវត្តិសាស្ត្រកំពុងតែចាប់ផ្ដើម មានដំណើរការគួរឲ្យកត់សំគាល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ សកម្មជនគាំទ្រគណបក្សសមរង្ស៊ីទាំងបុរសទាំងស្ត្រីបានចូលរួមក្នុងយុទ្ធនាការនេះយ៉ាងសកម្មដោយមានទឹកមុខពោរពេញដោយក្ដីសង្ឃឹមថានឹងទទួលបាននូវជ័យជំនះគួរជាទីពេញចិត្តនៅថ្ងៃទី២៧ ខែកក្កដាខាងមុខនេះ ។

រីឯយុទ្ធនាការស្វែងរកថវិកាឧបត្ថម្ភគណបក្សដែលបានចាប់ផ្ដើមជាផ្លូវការតាំងពីខែមករា ឆ្នាំ២០០៣ រហូតមកទល់ ថ្ងៃទី១២ ខែកក្កដានេះ ក៏បានប្រកបដោយជោគជ័យល្អប្រសើរជាទីបំផុតដែរ ។ គណបក្សសមរង្ស៊ី-សហរដ្ឋអាមេរិក រួមជាមួយសាខាតាមរដ្ឋ និងក្រុងនានាទូទាំងប្រទេស គិតមកទល់ថ្ងៃនេះ រកថវិកាបានដូចតាមគម្រោងសំរាប់ឧបត្ថម្ភដល់គណបក្សយើងក្នុងការចូលរួមប្រកួតប្រជែងបោះឆ្នោតសកលសំរាប់អណត្តិ ២០០៣-២០០៨ ៕

តាមរយៈនេះ ក្នុងនាមខ្ញុំជាប្រធានអនុគណកម្មការផ្នែកមូលនិធិ រួមជាមួយសមាជិក-ជិកានៃគណកម្មការប្រតិបត្តិនៃគណ-បក្ស សមរង្ស៊ីសាខាសហរដ្ឋអាមេរិក សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះសន្ដានចិត្តដ៏សប្បុរសជះថ្លារបស់អស់លោក-លោកស្រី ដែលបានរួមចំណែកក្នុងការផ្ដល់វិភាគទាន គាំទ្រយើងខ្ញុំជារៀងរហូតមកនេះ ។

ម៉្យាងទៀតយើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់សមាជិក-ជិកា និងថ្នាក់ដឹកនាំរបស់គណបក្សសាខាតាមរដ្ឋ និងទីក្រុងនានា ដែលមានជំនឿលើគោលនយោបាយគណបក្ស បានប្រឹងប្រែងយ៉ាងពេញទំហឹង គ្មានខ្លាចនឿយហត់ ឬខាតបង់ពេលវេលា ឬធនធានផ្ទាល់ខ្លួន សកម្មតាមតួនាទីរបស់ខ្លួន បំរើក្នុងយុទ្ធនាការនេះរហូតដល់បានសំរេច ។

តែ ទោះបីជាយើងបានជួបតាមទិសដៅរកថវិកាដូចខាងលើក៏ដោយ ជាទូទៅ គណបក្សរបស់យើងនៅភ្នំពេញនៅតែជួបប្រទះនឹងសេចក្ដីខ្វះខាតមួយចំនួនធំដែរ ហេតុដូច្នេះហើយ យើងខ្ញុំបន្តអំពាវនាវ សូមអស់លោក-លោកស្រីមេត្តាបន្តជួយផ្ដល់ថវិកាតទៅទៀត រហូតដល់ថ្ងៃបោះឆ្នោត ដើម្បីធានាជ័យជំនះដល់គណបក្សយើង ។ ចំពោះអស់លោក-លោកស្រីដែលមិនទាន់មានឱកាសជួយផ្ដល់វិភាគទាននៅឡើយ ហើយមានបំណងចូលរួមចំណែកក្នុងយុទ្ធនាការនេះ សូមទាក់ទងមកបណ្ដាញរបស់យើងតាមតំបន់និមួយៗដែលលោក-អ្នករស់នៅ ។ សូមកុំឲ្យឱកាសជាប្រវត្តិសាស្ត្រនេះកន្លងហួសទៅជាអសារឥតការ ។

ជាបញ្ចប់ សូមឲ្យស្មារតីស្នេហាជាតិ គំនិតស្រឡាញ់លទ្ធិប្រជាធិបតេយ្យ ជួយជំរុញឲ្យអស់លោក-លោកស្រី និងសមាជិក-ជិកា របស់គណបក្សសមរង្ស៊ីទាំងអស់ ក្នុងប្រទេស និងក្រៅប្រទេសរួបរួមសាមគ្គីគ្នាជាធ្លុងមួយដើម្បីអនាគតដ៏ភ្លឺស្វាងសំរាប់ប្រទេសកម្ពុជារបស់យើង ។

*អូឡាំព្យា, ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៣*

**ស៊ុម ធិត្យា**

*ប្រធានអនុគណៈកម្មាធិការផ្នែកមូលនិធិនៃ គសរ-សរអា*

**Sam Rainsy Party -U.S.A.** PO BOX 2067, Lowell, MA 01851 – FAX (508) 643-7212 – Website: www.srpusa.org